អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ២៤/២៣ ចេញផ្សាយ ខែធ្នូ ឆ្នាំ២០២៣

## ភាពខុសគ្នារវាងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃប្រតិបត្តិការ



ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ គឺជាដំណើរការនៃការប្រមូលព័ត៌មានជាបន្តបន្ទាប់ ដើម្បីធ្វើការវាយ-តម្លៃក្នុងគោលបំណង កំណត់ថាតើវឌ្ឍនភាពការងារបាននឹងកំពុងឆ្ពោះទៅរកគោលដៅ គោលបំណងដែលបានកំណត់ទុកជាមុនដែរឬទេ ព្រមទាំងបញ្ជាក់អំពីផលប៉ះពាល់នានាដែលអាចបង្កឡើងដោយការអនុវត្តសកម្មភាពការងារផងដែរ។ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃក៏ដើរតួយ៉ាងសំខាន់ណាស់នៅក្នុងកិច្ចប្រតិបត្តិការនានារបស់ស្ថាប័ន ព្រមទាំងជួយធានាថាស្ថាប័នបានអនុវត្តការងារស្របទៅតាមផែនការ។ ជាងនេះទៅទៀត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ក៏ជួយឱ្យស្ថាប័នអនុវត្តកិច្ចការនានាប្រកបដោយប្រសិទ្ធភាព, ប្រសិទ្ធផល, និងភាពសន្សំសំចៃផងដែរ។

### ១. ការតាមដានត្រួតពិនិត្យ




ការតាមដានត្រួតពិនិត្យ សំដៅដល់ដំណើរការនៃការប្រមូល ការវិភាគ និងការវាយតម្លៃព័ត៌មាននៃការអនុវត្តការងារជាទៀងទាត់ដើម្បីធ្វើការសម្រេចចិត្តបានទាន់ពេលវេលា និងសមស្រប ព្រមទាំងធានាបានថាការងារត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ បន្ថែមពីនេះ ការតាមដានត្រួតពិនិត្យ គឺជាការវាស់វែងការអនុវត្តការងារ ដើម្បីពិនិត្យមើលថាតើលទ្ធផលការងារស្របទៅតាមផែនការដែរឬទេ។

### ២. ការវាយតម្លៃ



ការវាយតម្លៃ សំដៅដល់ការប្រមូល និងវិភាគទិន្នន័យក្នុងការវាយតម្លៃភាពខ្លាំង និងភាពខ្សោយនៃការអនុវត្តផែនការ បន្ទាប់មកធ្វើការកែលម្អឱ្យមានប្រសិទ្ធភាព។ ជាទូទៅការវាយតម្លៃ ត្រូវបានធ្វើឡើងនៅពេលបញ្ចប់ការអនុវត្តសកម្មភាពដោយថ្នាក់ដឹកនាំ ហើយការវាយតម្លៃនេះក៏អាចធ្វើឡើងនៅពាក់កណ្តាលអាណត្តិផងដែរ។

### ៣. សមាសធាតុសំខាន់ៗសម្រាប់យន្តការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ



សមាសធាតុសំខាន់ៗសម្រាប់យន្តការតាមដានត្រួតពិនិត្យ និងការវាយតម្លៃរួមមាន៖ របាយការណ៍ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រតិបត្តិការ, យន្តការនៃការប្រមូលទិន្នន័យដែលជួយក្នុងការពិនិត្យវឌ្ឍនភាព និងសមិទ្ធផលធៀបទៅនឹងគោលដៅដែលបានគ្រោងទុក, មូលដ្ឋានគ្រឹះនៃការ


ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

ប្រមូលទិន្នន័យដោយមានក្របខណ្ឌនៃការវាយតម្លៃ, យន្ត-ការច្បាស់លាស់សម្រាប់រាយការណ៍, ការប្រើប្រាស់នូវលទ្ធផលដែលបានមកពីការតាមដានត្រួតពិនិត្យ និងការវាយតម្លៃក្នុងការធ្វើការសម្រេចចិត្ត, និងការរៀបចំផែនការប្រកបដោយចីរភាពដោយពឹងផ្អែកទៅលើទិន្នន័យ, ការគ្រប់គ្រង, ការវិភាគ, និងការរាយការណ៍ជាក់លាក់។

### ៤.សារៈសំខាន់នៃការតាមដានត្រួតពិនិត្យ និងការវាយ-តម្លៃ



ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ អាចជួយឱ្យស្ថាប័ន÷

- ស្វែងយល់អំពីការរីកចម្រើននានា ដែលឆ្ពោះទៅរកការសម្រេចគោលបំណង
- តាមដានប្រតិបត្តិការជាក់ស្តែង ដោយប្រៀបធៀបនឹងផែនការដែលបានដាក់ចេញ
- ធានាបានថាការប្រើប្រាស់ធនធានរបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- បម្រើសេវាកម្មដល់សាធារណជនប្រកបដោយគុណ-ភាព
- កំណត់បញ្ហាដែលអាចមានឡើង ឬកំពុងរាំងស្ទះប្រតិបត្តិការ និងឧបសគ្គនានាដែលពាក់ព័ន្ធដំណើរការងារ
- ដោះស្រាយបញ្ហាប្រឈមក្នុងដំណើរការអនុវត្តផែន-ការសកម្មភាពបានទាន់ពេលវេលាក្នុងករណីចាំបាច់ អាចកែលម្អផែនការ ឬដំណើរការប្រតិបត្តិការនានា ដើម្បីទទួលបានសមិទ្ធផលសមស្របនាពេលអនាគត
- ជាជំនួយស្មារតីដល់ថ្នាក់ដឹកនាំស្ថាប័នក្នុងការសម្រេចចិត្តសម្រាប់គ្រោងនឹងរៀបចំផែនការបន្ទាប់ប្រកបដោយប្រសិទ្ធភាព
- និងតម្រង់ទិសដៅការងារ។

### ៥.ភាពខុសគ្នាជាមូលដ្ឋានរវាងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

**ការតាមដានត្រួតពិនិត្យ**

- ផ្ទៀងផ្ទាត់ដំណើរការប្រតិបត្តិជាក់ស្តែងដែលគ្រោងនិងបន្តផ្ទៀងផ្ទាត់
- មានលក្ខណៈសាមញ្ញជាង
- អនុវត្តដោយផ្ទៃក្នុងស្ថាប័ន
- ជួយតម្រង់ទិសផែនការ និងកែលម្អប្រតិបត្តិការដើម្បីនាំឆ្ពោះទៅសម្រេចគោលដៅ និងគោលបំណងស្ថាប័ន។

**ការវាយតម្លៃ**

- ត្រួតពិនិត្យថាតើគោលដៅ និងគោលបំណងស្ថាប័នត្រូវសម្រេចបាន ឬធ្វើការប្រៀបធៀបការប្រែប្រួលស្ថានភាពស្ថាប័នមុន និងក្រោយអនុវត្តផែនការ
- រៀបចំប្រព័ន្ធបែបបទ និងបច្ចេកទេសច្បាស់លាស់
- អនុវត្តដោយផ្ទៃក្រៅ ឬផ្ទៃក្នុងស្ថាប័ន
- អាចធ្វើពាក់កណ្តាលអាណត្តិនៃផែនការ ឬពេលផែនការត្រូវបានបញ្ចប់ ឬមួយផែនការបានកំពុងបន្តអនុវត្ត ថាតើត្រូវកែលម្អអ្វីខ្លះ។

**អត្ថបទ÷ លោកស្រី អ៊ី សុនីតា**

**ឯកសារយោង÷**

ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**